**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-Jan-2014, 15:33
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឲ្យដាក់សារណា ទាក់ទិននឹងវិសាលភាពសំណុំរឿង ០០២/០២**

---

**<u>ដាក់ដោយ៖</u>**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

LIV Sovanna

Joshua ROSENSWEIG

**<u>ចម្លងជូន៖</u>**

**សហចៅក្រមស៊ើបអង្កេត**

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**<u>សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

សហមេធាវីការពារក្តី នួន ជា ("មេធាវីការពារ") សូមដាក់ចម្លើយតបនេះទៅនឹងសំណើសុំរបស់អង្គជំនុំជម្រះសាលាដំបូងសុំឲ្យដាក់សារណាទាក់ទិននឹងវិសាលភាពសំណុំរឿង០០២/០២ ៖

1. កាលពីថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានឲ្យភាគីទាំងអស់ដាក់សារណាជាលាយលក្ខណ៍អក្សរទាក់ទិននឹងវិសាលភាពនៃសំណុំរឿង០០២/០២ ត្រឹមថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤[1]។ មេធាវីការពារក្តីសូមដាក់សារណាទាំងនេះដែលទាក់ទិននឹងវិសាលភាពនៃសំណុំរឿង ០០២/០២ បន្ថែមលើបញ្ហាផ្សេងៗជាក់លាក់មួយចំនួនទៀត។

*វិសាលភាពនៃសំណុំរឿង ០០២/០២*

2. អនុលោមតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះតម្រូវឲ្យចាប់ផ្តើមសវនាការឲ្យបានឆាប់ៗតាមតែអាចធ្វើបាន បន្ទាប់ពីសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលនៅក្នុងសំណុំរឿង ០០២/០១ ហើយសវនាការនេះត្រូវតែតំណាងសមហេតុផលឲ្យដីកាដំណោះស្រាយសំណុំរឿង០០២។ បន្ថែមពីលើនេះ សវនាការនេះ ត្រូវតែរួមបញ្ចូលជាអប្បបរិមានូវបទចោទទាក់ទងនឹងមន្ទីរស-២១ អំពើប្រល័យពូជសាសន៍លើជនជាតិចាម និងជនជាតិវៀតណាម សហករណ៍ និងការដ្ឋានធ្វើការ[2]។

3. ផលប្រយោជន៍ចម្បងរបស់ នួន ជា ទាក់ទិននឹងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង០០២/០២ គឺថា គាត់មានឱកាសពេញលេញដើម្បីបង្ហាញភស្តុតាងដោះបន្ទុកក្នុងការគាំទ្រដល់ការការពារក្តីរបស់គាត់។ ដូចដែលមេធាវីការពារក្តីបានតវ៉ាជាយូរមកហើយ អង្គហេតុហួសពីវិសាលភាពចង្អៀតនៃបទចោទនៅក្នុងដីកាដំណោះស្រាយ គឺពាក់ព័ន្ធនឹងការបញ្ជាក់ការពិត[3]។ ក្នុងអំឡុងពេលការជំនុំជម្រះសំណុំរឿង០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់វិធីសាស្ត្រចង្អៀតជ្រុលហួស ដើម្បីទទួលយកភស្តុតាងដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ និងជាទូទៅ

---

[1] ឯកសារលេខ E301/5 "ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង០០២/០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារនាពេលខាងមុខ" កថាខណ្ឌ៥។

[2] ឯកសារលេខ E284/4/8 "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២" ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី") កថាខណ្ឌ៧៦។

[3] សូមមើល ឯកសារលេខ **E295/6/3** "សេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលសំណុំរឿង ០០២/០១" ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០១៣ កថាខ័ណ្ឌ ៥១ ដល់៥៩។

ស្ថិតនៅក្រៅដីកាដំណោះស្រាយ។

4. ហេតុដូច្នេះ ជំហររបស់ នួន ជា ទាក់ទិននឹងការបំបែកដីកាដំណោះស្រាយ គឺថាភស្តុតាងពាក់ព័ន្ធ ដែលរួមមានឯកសារ សាក្សីដែលអង្គជំនុំជម្រះកោះហៅ និងសំណួរដែលបានលើកឡើងនៅក្នុង អំឡុងពេលសួរដេញដោលផ្ទាល់ មិនត្រូវដកចេញពីកិច្ចដំណើរការនីតិវិធី ដោយសារតែភស្តុតាង ពាក់ព័ន្ធនេះ មិនទាក់ទងដោយផ្ទាល់ទៅនឹងទីកន្លែងឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងវិសាលភាពនៃ ការជំនុំជម្រះនោះទេ។ ភស្តុតាងណាក៏ដោយអំពីកម្មវត្ថុណាមួយនៅក្នុងវិសាលភាពនៃដីកាដំណោះ ស្រាយនៅក្នុងសំណុំរឿង០០២ ត្រូវចាត់ទុកថាពាក់ព័ន្ធ និងអាចទទួលយកបាន*ជាបឋម*។ ភស្តុតាង អំពីកម្មវត្ថុដែលស្ថិតនៅក្រៅដីកាដំណោះស្រាយសំណុំរឿង០០២ គួរត្រូវបានអនុវត្តដោយមានការ យោគយល់ជាងការអនុវត្តភ័ស្តុតាងក្នុងអំឡុងពេលជំនុំជម្រះសំណុំរឿង០០២/០១។ ឧទាហរណ៍ ផ្នែកសំខាន់នៃការសួរសំណួរ អាចរួមបញ្ចូលចំនួនសរុបនៃការបាត់បង់ជីវិតនៅក្នុងអំឡុងពេល កម្ពុជាប្រជាធិបតេយ្យ និងជម្លោះនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។

5. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ក្របខណ្ឌគតិយុត្តរបស់អ.វ.ត.ក អនុញ្ញាតឲ្យអង្គជំនុំ ជម្រះស្តាប់សក្ខីកម្មទាក់ទិននឹងផ្នែកនៃបទចោទនៅក្នុងដីកាដំណោះស្រាយ[4]។ ដោយពិចារណាលើ ការសម្រេចនេះ មេធាវីការពារក្តីយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា សំណុំរឿង០០២/០២ គួរតែជាការជំនុំជម្រះចុងក្រោយនៃដីកាដំណោះស្រាយក្នុងសំណុំរឿង០០២។ ការជំនុំជម្រះបែប នេះ នឹងលែងមានភាពមិនច្បាស់លាស់នាពេលអនាគតទាក់ទិននឹងការកាត់សេចក្តីចំពោះបទចោទ បន្ថែមនៅក្នុងការជំនុំជម្រះក្រោយៗទៀត និងអនុញ្ញាតឲ្យភាគីចូលរួមដោយសេរីជាមួយភស្តុតាង ដែលទាក់ទិននឹងដីកាដំណោះស្រាយពេញលេញ។ ជម្លោះដែលពាក់ព័ន្ធនឹងបញ្ហា "ដែលស្ថិតនៅ ក្រៅវិសាលភាពនៃការជំនុំជម្រះ" លែងមានដូចអតីតកាលទៀតហើយ។

6. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង ពិតជាមានចេតនាកំណត់លក្ខណៈចង្អៀតលើវិសាលភាពនៃ ការសួរសំណួរ ក្នុងអំឡុងពេលសំណុំរឿង០០២/០២ចំពោះទីកន្លែងឧក្រិដ្ឋកម្មដោយផ្ទាល់មែននោះ នួន ជា ត្រូវបានបង្ខំឲ្យទទូចស្នើសុំឲ្យអង្គជំនុំជម្រះរួមបញ្ចូលនៅក្នុងវិសាលភាពនោះនូវទីកន្លែង ឧក្រិដ្ឋកម្ម ដែលតាមរយៈវិសាលភាពនេះ គាត់ទំនងជាអាចបង្ហាញនូវអង្គហេតុដែលពាក់ព័ន្ធនឹង ការការពារក្តីជាវិជ្ជមានរបស់គាត់។ មេធាវីការពារក្តីបានធ្វើសំណើស្រដៀងគ្នាមួយនៅក្នុងសំណុំ រឿង០០២/០១ ស្នើសុំការកាត់សេចក្តីអំពីសហករណ៍ និងការដ្ឋានធ្វើការ ដែលជាមធ្យោបាយនៃ

[4] *សូមមើល* កថាខណ្ឌ ៩ ដល់ ១១ ខាងក្រោម។

ការបង្ហាញអំពីចេតនារបស់ នួន ជា ទាក់ទិននឹងការជម្លៀសចេញពីទីក្រុងភ្នំពេញ[5]។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធចោលសំណើសុំនោះ ដោយផ្អែកលើមូលដ្ឋានថា ភាគីមានសិទ្ធិបង្ហាញភស្តុតាងដែលពាក់ព័ន្ធនឹងបទចោទ[6]។ ទោះបីជាយ៉ាងណាក៏ដោយ ផ្អែកតាមការអនុវត្ត ការដាក់កំហិតដែលបង្ខំដោយដីកាបំបែកកិច្ចដំណើរការនីតិវិធី បានបង្កើតនូវការវាយតម្លៃទូលំទូលាយលើគោលនយោបាយសហករណ៍ ហេតុដូច្នេះចេតនារបស់ នួន ជា ទាក់ទិននឹងការជម្លៀសចេញពីទីក្រុងភ្នំពេញ មិនអាចធ្វើទៅរួចនោះទេ។

7. នៅក្នុងសំណុំរឿង ០០២/០២ អង្គហេតុដែលចាំបាច់សម្រាប់ការការពារក្តីរបស់ នួន ជា រួមមានជាអាទិ៍នូវការចងសម្ព័ន្ធរវាងកងកម្លាំងភូមិភាគពាយព្យ ជាមួយនឹងភូមិភាគបូព៌ា ប្រឆាំងនឹងប៉ុល ពត និង នួន ជា និងតួនាទីរបស់រដ្ឋាភិបាលវៀតណាម ក្នុងការគាំទ្រការប្រឆាំងទាំងនេះក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល។ បទចោទសំខាន់បំផុត គឺបទចោទទាំងឡាយណាដែលចោទប្រកាន់ថាបានកើតឡើងនៅភូមិភាគពាយ័ព្យ និងបូព៌ា៖ (i) ការដ្ឋានទំនប់ត្រពាំងថ្ម (កថាខណ្ឌ៣២៣ ដល់៣៥០ នៃដីកាដំណោះស្រាយ), (ii) មន្ទីរសន្តិសុខវត្តគីរីរម្យ (កថាខណ្ឌ៥៥១ ដល់៥៧១ នៃដីកាដំណោះស្រាយ) ឬមន្ទីរសន្តិសុខវត្តធ្លក (កថាខណ្ឌ ៦៤៤ ដល់ ៦៦៦ នៃដីកាដំណោះស្រាយ) (iii) គោលការណ៍បោសសម្អាតផ្ទៃក្នុងដែលចោទប្រកាន់ (កថាខណ្ឌ ១៩២-២០៣ នៃដីកាដំណោះស្រាយ) និង (iv) ការជម្លៀសប្រជាជនដំណាក់កាលទីបីដែលចោទប្រកាន់ (កថាខណ្ឌ ២៨៣ ដល់ ៣០១ នៃដីកាដំណោះស្រាយ)។

*ភាពលម្អៀង*

8. ឆ្លើយតបទៅនឹងសំណួរផ្ទាល់មាត់ពីអង្គជំនុំជម្រះ[7] មេធាវីការពារក្តីកត់សម្គាល់ឃើញថា នឹងមានលទ្ធភាពច្រើនដែលនឹងស្នើសុំឱ្យសមាជិកណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានជំនុំជម្រះសំណុំរឿង ០០២/០១ ឱ្យដកខ្លួនចេញពីសំណុំរឿង ០០២/០២។ បើតាមការវាយតម្លៃរបស់មេធាវីការពារ ទោះបីជាការសម្រេចជាស្ថាពរមិនអាចធ្វើឡើងរហូតដល់ចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០១ តែការសម្រេចរបស់អង្គជំនុំជម្រះនេះនៅក្នុងសំណុំរឿង០០១ អាចជា

---

[5] ឯកសារលេខ **E284/4/1** “បណ្តឹងសារទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដមណើការនីតិវិធី និសារណាតបចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ជំទាស់នឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី” ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១២ ដល់ ១៥។

[6] សេចក្តីសម្រេចរបស់អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ៥២។

[7] ឯកសារលេខ E1/238.1 “ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី” ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣ ទំព័រ 95:1-98:14។

មូលដ្ឋានគ្រប់គ្រាន់សម្រាប់បណ្តឹងបែបនេះទាក់ទិននឹងមន្ទីរស-២១[8]។ ការកឃើញរបស់អង្គជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ ទំនងជាត្រូវបានគូសបញ្ជាក់អំពីការបារម្ភសមហេតុផលអំពីភាពលំអៀង និងជាមូលដ្ឋានសម្រាប់ដាក់បណ្តឹងជំទាស់អង្គចៅក្រមផ្ទៃក្នុង។

*បទចោទ ដែលមិនបានរួមបញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២*

9. បញ្ហាចុងក្រោយមួយ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលមិនត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២។ ថ្មីៗនេះ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីណែនាំទាក់ទិននឹងបញ្ហានេះ និងបានទទួលស្គាល់យ៉ាងច្បាស់អំពី "កាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង សម្រេចលើបញ្ហាដែលពុំទាន់បានជំនុំជម្រះរួចនៅចំពោះមុខខ្លួន ដូច្នេះកិច្ចដំណើរការនីតិវិធីលើបទចោទព្រហ្មទណ្ឌ ត្រូវបានសម្រេចលើអង្គសេចក្តី ឬត្រូវបដិសេធចោល"[9]។ នៅក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូលបានប្រើប្រាស់គោលការណ៍របស់ប្រទេសបារាំងដែលសវនាការជំនុំជម្រះត្រូវតែដោះស្រាយបណ្តឹងឲ្យអស់នៅចំពោះមុខអង្គជំនុំជម្រះ *(vider sa saisine)* [10]។ អាស្រ័យហេតុនេះ បទចោទដែលមាននៅក្នុងដីកាដំណោះស្រាយ មិនអាចត្រូវអង្គជំនុំជម្រះទុកចោលដោយមិនដោះស្រាយឡើយ[11]។ ដំណោះស្រាយជាក់លាក់មួយត្រូវតែមាន។

10. បញ្ហានៅតែមិនទាន់ដោះស្រាយ ក្រោយការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធនឹងលក្ខណៈច្បាស់លាស់នៃដំណោះស្រាយនោះ។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា សិទ្ធិរបស់សហព្រះរាជអាជ្ញាក្នុងការទម្លាក់ចោលការចោទប្រកាន់ មិនត្រូវ "រារាំង" នៅ អ.វ.ត.ក ក៏អង្គជំនុំជម្រះតុលាការកំពូលមិនបានផ្តល់នូវសិទ្ធិសេរីភាពឲ្យសហព្រះរាជអាជ្ញាទម្លាក់ចោលការចោទប្រកាន់នោះទេ។ ប៉ុន្តែ សហព្រះរាជអាជ្ញាមានសិទ្ធិដកការចោទប្រកាន់ បន្ទាប់ពី "ការពិចារណាអំពីផលប្រយោជន៍យុត្តិធម៌ និងសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ដែលពាក់ព័ន្ធ"[12]។ អង្គជំនុំជម្រះតុលាការកំពូល ខកខានមិនបានបញ្ជាក់ថាផលប្រយោជន៍យុត្តិធម៌ណាមួយដែលអាចធ្វើយុត្តិកម្មចំពោះសេចក្តីសម្រេចបែបនេះ នៅក្នុងក្របខណ្ឌនីតិវិធីរបស់ អ.វ.ត.ក។

---

[8] ឯកសារលេខ E54 "បណ្តឹងជំទាស់ជាបន្ទាន់ចំពោះចៅក្រមអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១។

[9] សេចក្តីសម្រេចរបស់អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ៦២។

[10] សេចក្តីសម្រេចរបស់អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ជើងទំព័រ ១៧៦។

[11] សេចក្តីសម្រេចរបស់អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៤៣។

[12] សេចក្តីសម្រេចរបស់អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ៦១។

11. អង្គជំនុំជម្រះតុលាការកំពូល ក៏បានទទួលស្គាល់អំពីលទ្ធភាពនៃ "សេចក្តីសម្រេច[របស់អង្គជំនុំជម្រះសាលាដំបូង] អំពីការបិទសំណុំរឿង ដែលពុំបានប្រកាសអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ"[13]។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូល មិនបានប្រៀបធៀប "សេចក្តីសម្រេចស្តីពីការបិទសំណុំរឿង"នេះ ទៅនឹងនីតិវិធីជាតិ ឬអន្តរជាតិនោះទេ។ ឧទាហរណ៍នៃច្បាប់ស៊ីវិលដែលអង្គជំនុំជម្រះដកស្រង់ពីក្រមនីតិវិធីព្រហ្មទណ្ឌអាឡឺម៉ង់ ចែងអំពីការកាត់បន្ថយយ៉ាងច្រើននៃបទចោទ ដែលមិនអាចអនុវត្តចំពោះទម្រង់ទូលាយនៃដីកាបំបែកកិច្ចដំណើរការនីតិវិធី ផ្អែកតាមការពិចារណានៅចំពោះមុខអង្គជំនុំជម្រះនេះ[14]។ បន្ថែមពីលើនេះ អង្គជំនុំជម្រះតុលាការកំពូលក៏បានទទួលស្គាល់ថា យុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិល បានហាមឃាត់ការអនុវត្តបែបនេះ ហើយបានកត់សម្គាល់ថា ផ្អែកតាមច្បាប់កម្ពុជា ការចោទប្រកាន់អាចនឹងត្រូវបដិសេធចោល តែនៅក្នុងកាលៈទេសៈដែលត្រូវបានកំណត់យ៉ាងចង្អៀត និងជាក់លាក់[15]។ បើតាមការយល់ដឹងរបស់មេធាវីការពារក្តី នីតិវិធីបែបនេះ មិនមាននោះទេនៅក្នុងនីតិវិធីបារាំង ដែលក្រមរបស់ប្រទេសកម្ពុជាផ្អែកលើ។ អាស្រ័យហេតុនេះ សំណួរជាច្រើន នៅតែមិនទាន់មានចម្លើយអំពីប្រភេទនៃសេចក្តីសម្រេចបែបនេះ។ សំខាន់ជាងនេះ តើករណីនេះសាកសមនៅក្នុងកាលៈទេសៈណាមួយ ហើយតើការចោទប្រកាន់ក្រោយៗ ត្រូវបានចោទប្រកាន់ដោយអំណាចអយ្យការ ឬតុលាការនៅក្រៅក្របខណ្ឌរបស់ អ.វ.ត.ក ឬទេ?

12. នៅក្នុងសំណុំរឿងនេះ ការវាយតម្លៃរបស់អង្គជំនុំជម្រះលើផលប្រយោជន៍យុត្តិធម៌ និងសិទ្ធិរបស់ជនជាប់ចោទទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ត្រូវតែយកមកពិចារណាទាំងភាពជាក់ស្តែងផ្នែកនីតិវិធី និងនយោបាយនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។ ចំពោះសេចក្តីសម្រេចដក ឬបញ្ចប់ការចោទប្រកាន់ មិនមានយុត្តិសាស្ត្រច្បាស់លាស់នៅក្នុងនីតិវិធីអន្តរជាតិ ឬជាតិនោះទេ ដោយសារតែឋានានុក្រមគតិយុត្តិនៃការចោទប្រកាន់ទាំងនោះ មានលក្ខណៈមិនទាន់ច្បាស់លាស់ ដូចនេះតុលាការជាតិអាចមានលទ្ធភាពស្វែងរកចោទប្រកាន់បទចោទទាំង

---

[13] សេចក្តីសម្រេចរបស់អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ៦៣។

[14] នីតិវិធីរបស់អាឡឺម៉ង់ ដែលដកស្រង់ដោយអង្គជំនុំជម្រះតុលាការកំពូល ចែងអំពីការបំបែកកិច្ចដំណើរការនីតិវិធីលើ "ផ្នែកនៃ" បទចោទ ឬការរំលោភបំពានច្បាប់មួយចំនួនដែលបានប្រព្រឹត្ត ថាជាផ្នែកមួយនៃបទល្មើសដែលត្រូវបានចោទប្រកាន់។ *សូមមើល* សេចក្តីសម្រេចរបស់អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ជើងទំព័រ១៧៣។ ផ្នែកដែលត្រូវបានបំបែក ត្រូវតែ "មិនត្រូវសំខាន់ជាពិសេសនោះទេ"។

[15] សេចក្តីសម្រេចរបស់អ.ជ.ត.ក ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ជើងទំព័រ១៧៤។

នោះនាពេលអនាគត មិនអាចដកចេញបាននោះទេ[16]។ ជាការពិត អង្គជំនុំជម្រះនេះ បានសម្រេចពីមុនថា សាលក្រមលើអង្គសេចក្តី មិនបានបណ្តាលឱ្យមានការអនុវត្តនូវ *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ផ្អែកតាមច្បាប់កម្ពុជា នៅពេលដែលការជំនុំជម្រះដំណើរការនីតិវិធីធ្វើឡើងដោយ *កំបាំងមុខ*[17]។

13. អង្គជំនុំជម្រះនេះ ចាំបាច់ត្រូវធានាថា ការចោទប្រកាន់ដែលមាននៅក្នុងដីកាដំណោះស្រាយ មិនត្រូវយកមកកាត់សេចក្តីឱ្យលើសពីក្របខណ្ឌរបស់ អ.វ.ត.ក។ ការស៊ើបអង្កេតសំណុំរឿង ០០២ (និង ការឃុំខ្លួនរបស់ នួន ជា) បានបន្តជាងប្រាំមួយឆ្នាំ ហើយសាលដីកាលើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០២ ទំនងជាមិនមែនប្រើរយៈពេលបីបួនឆ្នាំទៀតនោះទេ។ កិច្ចដំណើរការនីតិវិធីជាបន្តបន្ទាប់ ស្ទើរតែរំលោភបំពានយ៉ាងច្បាស់លើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីឆាប់រហ័សមួយ។ កិច្ចដំណើរការនីតិវិធីបែបនេះ នឹងធ្វើឱ្យខូចដល់មូលដ្ឋាននៃអត្ថិភាពរបស់អង្គជំនុំជម្រះនេះ ដែលការជំនុំជម្រះយុត្តិធម៌មួយ មិនអាចមាននោះទេនៅក្នុងយុត្តាធិការធម្មតារបស់ប្រទេសកម្ពុជា[18]។ ផលប្រយោជន៍យុត្តិធម៌ និងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ តម្រូវឱ្យអង្គជំនុំជម្រះនេះចេញសាលក្រមស្ថាពរមួយលើអង្គសេចក្តី ទាក់ទិននឹងរាល់បទចោទទាំងអស់នៅក្នុងដីកាដំណោះស្រាយ និងធានាថា មិនមានដំណើរការនីតិវិធីនាណាមួយលើបទចោទទាំងនោះនាពេលអនាគតម្តងទៀតនោះទេ។

14. អភវនីយភាពនៃកិច្ចដំណើរការនីតិវិធីនាពេលអនាគតប្រឆាំងលើ នួន ជា មិនមែនជាការពិចារណាពាក់ព័ន្ធនៅក្នុងករណីនេះទេ។ អង្គជំនុំជម្រះ ពីមុនបានបំពេញតួនាទីការពារសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ ឌុច និងការប៉ះពាល់សិទ្ធិរបស់នួន ជា ដែលត្រូវបានសួរដេញដោលលើភស្តុតាងប្រឆាំងលើរូបគាត់ ដោយសារតែហានិភ័យដែលថា គាត់អាចនឹងត្រូវបានចោទប្រកាន់ពេលក្រោយ

---

[16] អនុលោមតាមមាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាអស់ជំនុំ អនុវត្តចំពោះ "ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ"។

[17] ឯកសារលេខ E51/15 "សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស" ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ៣០។

[18] David Scheffer "អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា" ទំព័រ៥, ៩-១០ ដែលអាចរកបាននៅ http://www.cambodiatribunal.org/wp-content/uploads/2013/08/history_history-analysis-scheffer_english.pdf.។

ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថាបានប្រព្រឹត្តនៅ ម-១៣[19]។ សហព្រះអាជ្ញាបានគាំទ្រថា ការសម្រេចផ្អែកលើមូលដ្ឋានថា "វាតែងតែនៅមានលទ្ធភាពចោទប្រកាន់"[20]។ នៅក្នុងករណីណាក៏ដោយ លទ្ធភាពដែលបទចោទអាចត្រូវបានចោទប្រកាន់ គឺពាក់ព័ន្ធនឹងសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់[21]។

15. ជាចុងក្រោយ រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញនូវឆន្ទៈរបស់ខ្លួនដើម្បីបញ្ជាក់អំពីធាតុផ្សំនៃកំហុសរបស់ នួន ជា ដោយផ្អែកតាមក្រឹត្យច្បាប់ តាមរបៀបមួយដែលប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិផ្នែកច្បាប់របស់គាត់ រួមបញ្ចូលទាំងសិទ្ធិនិយាយស្តីដោយសេរី[22]។ អត្ថិភាពនៃដីកាតុលាការ ដែលរកឃើញនូវកំហុស នួន ជា ដោយផ្អែកលើសមតុល្យនៃភវនីយភាព ដូចដែលដីកាដំណោះស្រាយបានប្រើប្រាស់ បានធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពនេះ។ ដោយពិចារណាទៅលើកិច្ចខិតខំជាសាធារណៈរបស់នាយករដ្ឋមន្ត្រី និងសមាជិកឈានមុខផ្សេងទៀតរបស់រដ្ឋាភិបាលកម្ពុជា ដែលកំណត់ នួន ជា "ជាឃាតករ" និង "ជនប្រល័យពូជសាសន៍" និងភាពជាក់ស្តែងនៃនយោបាយកម្ពុជា ដូចនេះសេចក្តីថ្លែងការណ៍ច្បាស់មួយពីអង្គជំនុំជម្រះដែលថា សហព្រះរាជអាជ្ញាបានខកខានក្នុងការបង្ហាញអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ទាក់ទិននឹងបទចោទដែលមិនបានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០២ គឺជាផលប្រយោជន៍យុត្តិធម៌ និងពិតជាចាំបាច់។

**សហមេធាវីរបស់ នួន ជា**

**សុន អរុណ** **Victor KOPPE**

---

[19] ឯកសារលេខ E1/58.1 "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី" ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១២ ទំព័រ72:10-73:5។

[20] ឯកសារលេខ E1/58.1 "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី" ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ ទំព័រ 74:24 ។

[21] ទស្សនរបស់ Advocate General Ruiz-Jarabo Colomer ថ្លែងនៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០២ ក្នុង C-187/05 និង C-385/01 Götzüok និង Brügge [2003] ECR I-5859 កថាខណ្ឌ ៤៩ (សិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់ គឺជាគោលការណ៍សំខាន់មួយក្នុងចំណោមគោលការណ៍ពីរនៃ ne bis in idem )។

[22] ឯកសារលេខ E284/4/2 "សារណាបន្ថែមចំពោះបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី" ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣។